# ការបង្ហាញព័ត៌មានទាន់ពេល

ឈ្មោះក្រុមហ៊ុនចុះបញ្ជី : កំពង់ផែស្វយ័តក្រុងព្រះសីហនុ
លេខកូដក្រុមហ៊ុនចុះបញ្ជី : KH1000060009
កាលបរិច្ឆេទនិងពេលវេលានៃការបញ្ជូន : ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ ម៉ោង១៥:៣០នាទី

ហេតុការណ៍ពាក់ព័ន្ធនឹងការគ្រប់គ្រង ( ទម្រង់ គ.២ )

| សេចក្តីប្រកាសព័ត៌មានស្តីពី លទ្ធផលកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិក | |
|---|---|
| ១. កាលបរិច្ឆេទប្រជុំ | ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ |
| ២. របៀបវារៈ | ម៉ោង ០៧:៣០ ការចុះវត្តមាន ភាគហ៊ុនិកចូលរួម<br>ម៉ោង ០៨:១៥ គណៈអធិបតី និងភ្ញៀវកិត្តិយសអញ្ជើញមកដល់<br>ម៉ោង ០៨:៣០ - ប្រកាសសមាសភាពគណៈអធិបតី និងភ្ញៀវកិត្តិយស<br>- គោរពទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា និងគោរពវិញ្ញាណក្ខន្ធ<br>ម៉ោង ០៨:៤៥ មតិស្វាគមន៍របស់ប្រធានមហាសន្និបាតភាគហ៊ុនិក<br>ម៉ោង ០៩:០០ មតិចូលរួមរបស់ក្រុមហ៊ុនជប៉ុន KAMIGUMI Co., Ltd. និង Kobe - Osaka International Port Corporation<br>ម៉ោង ០៩:២០ មតិណែនាំនិងផ្តាំផ្ញើរបស់ **ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន<br>ម៉ោង ០៩:៤០ - របាយការណ៍ស្តីពីលទ្ធផលការងារអាជីវកម្ម-សេវាកម្មឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦<br>- សំណួរ-ចម្លើយ<br>- ដំណើរនិវត្តន៍របស់ **ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន<br>ម៉ោង ១០:២០ ការណែនាំអំពីនីតិវិធី សម្រាប់ការបោះឆ្នោតបែងចែកភាគលាភ ជូនភាគហ៊ុនិកសម្រាប់ឆ្នាំ២០២៥ និងប្រាក់លាភការក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋអម កសស សម្រាប់ឆ្នាំ២០២៦<br>ម៉ោង ១០:៣០ ប្រកាសបើក និងដំណើរការបោះឆ្នោតរយៈពេល ៣០នាទី<br>ម៉ោង ១១:០០ ប្រកាសលទ្ធផល និងមតិបិទកម្មវិធី |
| ៣. សេចក្តីសង្ខេបនៃលទ្ធផលប្រជុំ | - របាយការណ៍ស្តីពី លទ្ធផលអាជីវកម្ម-សេវាកម្ម ឆ្នាំ២០២៥<br>- របាយការណ៍ស្តីពី លទ្ធផលហិរញ្ញវត្ថុ ឆ្នាំ២០២៥ (បានធ្វើសវនកម្ម)<br>- ទិសដៅអនុវត្តការងារឆ្នាំ២០២៦<br>- ការអនុម័តការបែងចែកភាគលាភជូនភាគហ៊ុនិក សម្រាប់ឆ្នាំ២០២៥<br>• ភាគហ៊ុនិកប្រភេទ "ខ" មានចំនួន ៥.០០០.០០០ ដុល្លារអាមេរិក (≈ ២០.០០០.០០០.០០០ រៀល)<br>• ភាគហ៊ុនិកប្រភេទ "គ" មានចំនួន ១២.៩៧៣.០១០.១៦០ រៀល<br>- ការអនុម័តលើប្រាក់លាភការសម្រាប់ក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋ ឆ្នាំ២០២៦ ។ |
| ៤. ផ្សេងៗ | |

- ឯកសារភ្ជាប់៖ សេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី៩ របស់ កសស

**ហត្ថលេខា និងឈ្មោះបុគ្គលិក**
**ទទួលបន្ទុកផ្នែកការផ្តល់ព័ត៌មាន**

**ពិត ច្រាភ័ជ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

លេខ: ០២៦ សជណ/កសស/រប.ធម

ថ្ងៃព្រហស្បតិ៍ ១១កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ខេត្តព្រះសីហនុ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២៦

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលមហាសន្និបាតភាគហ៊ុនិក លើកទី៩ របស់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស)

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (កសស) សូមជម្រាបជូនវិនិយោគិន និងសាធារណជនមេត្តាជ្រាបថា៖ នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ វេលាម៉ោង ០៧:៣០ ព្រឹក កសស បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី៩ ក្រោមអធិបតីភាព ឯកឧត្តម **ប៉េង ពោធិ៍នា** រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន អមដោយ ឯកឧត្តម **លូ គឹមឈន់** ប្រធានក្រុមប្រឹក្សាភិបាល និងជាប្រធានមហាសន្និបាតភាគហ៊ុនិកលើកទី៩ ។ អង្គមហាសន្និបាតភាគហ៊ុនិកលើកទី៩ បានរៀបចំឡើងនៅ សណ្ឋាគារ សុខា បិច រីសត, ខេត្តព្រះសីហនុ ដែលមានកូរ៉ុម ចំនួន ៩៣,៩៤ % និងភាគហ៊ុនិកចំនួន ៧៥ រូប ស្មើនឹង ៨០.៥៧៣.០៣៦ ភាគហ៊ុន ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- របាយការណ៍ស្តីពី លទ្ធផលអាជីវកម្ម-សេវាកម្ម ឆ្នាំ២០២៥
- របាយការណ៍ស្តីពី លទ្ធផលហិរញ្ញវត្ថុ ឆ្នាំ២០២៥ (បានធ្វើសវនកម្ម)
- ទិសដៅអនុវត្តការងារឆ្នាំ២០២៦
- ការអនុម័តលើ ការបែងចែកភាគលាភជូនភាគហ៊ុនិក សម្រាប់ឆ្នាំ២០២៥
  - ភាគហ៊ុនិកប្រភេទ "ខ" មានចំនួន ៥.០០០.០០០ ដុល្លារអាមេរិក (≈ ២០.០០០.០០០.០០០ រៀល)
  - ភាគហ៊ុនិកប្រភេទ "គ" មានចំនួន ១២.៩៧៣.០១០.១៦០ រៀល
- ការអនុម័តលើ ប្រាក់លាភការសម្រាប់ក្រុមប្រឹក្សាភិបាល និងមន្ត្រីត្រួតពិនិត្យរដ្ឋ ឆ្នាំ២០២៦ ។

អង្គមហាសន្និបាតភាគហ៊ុនិកលើកទី៩ បានបិទបញ្ចប់នៅវេលាម៉ោង ១១:៣០ នាទីព្រឹក នាថ្ងៃខែឆ្នាំដដែលក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល និងការទទួលខុសត្រូវខ្ពស់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបជាព័ត៌មាន ។

**កំពង់ផែស្វយ័តក្រុងព្រះសីហនុ**

PORT AUTONOME DE SIHANOUKVILLE

តិរវិថី សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
Terak Vithei Samdech Akka Moha Sena Padei Techo HUN SEN
Sangkat Nº 3, Preah Sihanouk City, Preah Sihanouk Province
Office : 034 933 416; SPSEZ : 034 933 511; Pilot : 034 933 507
E-mail: pasinfo@pas.gov.kh;spsez@pas.gov.kh
Website: www.pas.gov.kh